ប្រចាំខែមេសា និងឧសភា ឆ្នាំ២០២៣

អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

# ព័ត៌មានអំពីសាលាISSRថ្នាក់បឋមសិក្សា

ត្រីមាសទី៣ ថ្ងៃព្រហស្បតិ៍ ទី១១ ខែឧសភា ឆ្នាំ២០២៤

## ដំណើរទស្សនកិច្ចសិក្សា

យើងខ្ញុំទាំងអស់គ្នាបានជម្រុញ និងលើកទឹកចិត្តដល់កូនៗសិស្សានុសិស្ស ទទួលបាននូវគំនិតអភិវឌ្ឍថ្មី និងបទពិសោធន៍រួមគ្នាមួយដើម្បីក្លាយខ្លួនជាធនធានមានសមត្ថភាពពេញលេញគ្រប់គ្រាន់ ប្រកបដោយគុណភាពក្នុងពិភពលោក។ ការសិក្សាមុខវិជ្ជាគណិតវិទ្យា និងអក្សរសាស្រ្តអង់គ្លេស ឬមុខវិជ្ជាផ្សេងៗក្នុងថ្នាក់រៀនតែមួយមុខគឺមិនទាន់គ្រប់គ្រាន់ទេ សកម្មភាពសិក្សានានាខាងក្រៅថ្នាក់ ដូចជាដំណើរទស្សនកិច្ចសិក្សា ក៏មានសារៈសំខាន់ និងចាំបាច់ដូចគ្នាផងដែរដើម្បីឲ្យពួកគេទទួលបានចំណេះដឹងបន្ថែមទៀត។
ការសិក្សាក្នុងថ្នាក់ និងក្រៅថ្នាក់រៀនគឺជាការផ្តល់ឱកាសដល់ពួកគេសិក្សាស្វែងយល់កាន់តែស៊ីជម្រៅអំពីមេរៀនជីវិតក្នុងសង្គម និងពិភពលោកជាក់ស្តែង ហើយអាចត្រៀមខ្លួនរៀបចំជីវិតថ្មីផងដែរ។

គ្រឹះស្ថានសិក្សាមួយចំនួនមិនសូវជាបានគិតគូរពីភាពចាំបាច់ និងសារៈសំខាន់នៃសកម្មភាពសិក្សាក្រៅថ្នាក់ ។ យើងខ្ញុំនឹងបង្ហាញលោក លោកស្រីពីសារៈសំខាន់ និងភាពចាំបាច់តម្រូវឲ្យគ្រឹះស្ថានសិក្សាត្រូវមានដំណើរទស្សនកិច្ចសិក្សាដល់សិស្ស និងរួមចំណែកដល់ការអប់រំឲ្យមានលក្ខណៈទូលំទូលាយ។







Ring Road St., Kor Kranh village, Siem Reap Commune. P O Box 93169, Post Code, 171209,
Siem Reap Province, Kingdom of Cambodia. Tel: (+855) 012 878 782/081 878 782 admin@issr.edu.kh

## ១. ការសិក្សាអន្តរកម្ម

ដំណើរទស្សនកិច្ចសិក្សាអាចជួយឲ្យកូនៗសិស្សានុសិស្សមានទំនាក់ទំនងអន្តរកម្មនូវអ្វីដែលពួកគេបានសិក្សាតាមរយៈសៀវភៅ បទពិសោធន៍សិក្សាតាមរយៈការអាន និងការចូលរួមសកម្មភាពនានា។



## ២. ការយល់ដឹងអំពីបរិយាកាសផ្សេងៗគ្នា

ដំណើរទស្សនកិច្ចសិក្សា អាចឱ្យសិស្សយល់ដឹងពីបរិបទខាងក្រៅ និងចេះរិះរកមធ្យោបាយដោះស្រាយបញ្ហាដោយខ្លួនឯង មិនចាំបាច់ត្រូវការជំនួយពីសាលា ឬគ្រូបង្រៀនឡើយ។ ពួកគេចាប់ផ្តើមមើលឃើញថាអ្វីដែលពួកគេរៀននៅក្នុងថ្នាក់រៀនអាចជួយពួកគេដោះស្រាយបញ្ហាជាក់ស្តែងបាន។



## ៣. អន្តរកម្មសង្គម

ការបន្ថែមដំណើរទស្សនៈកិច្ចក្រៅពីការសិក្សាក្នុងថ្នាក់ធ្វើឱ្យសិស្សទទួលបានបរិយាកាសសង្គមខុសៗគ្នា។ ពួកគេបានជួបក្រុមមនុស្សវ័យផ្សេងៗគ្នា ហើយអាចមានទំនាក់ទំនងគ្នាក្នុងអំឡុងពេលធ្វើដំណើរទស្សនកិច្ចសិក្សាជាដើម។ ជំនាញអន្តរកម្មថ្មីទាំងនេះផ្តល់ឱ្យពួកគេនូវមេរៀនដ៏សំខាន់អំពីការប្រព្រឹត្តឥរិយាបថផ្សេងៗ ទៅតាមបរិបទជាក់ស្តែង។ អ្វីដែលពិសេសជាងនេះ ដំណើរទស្សនកិច្ចសិក្សា ជាកត្តាជំរុញឲ្យសិស្សរៀនធ្វើការងារជាក្រុមក្នុងសហគមន៍ជាមួយគ្នាបានយ៉ាងល្អថែមទៀតផង។



## ៤. កំណើនសេដ្ឋកិច្ចសង្គម



និយាយឱ្យសាមញ្ញ សិស្សដែលបានចូលរួមដំណើរទស្សនកិច្ចសិក្សាគឺមានទំនាក់ទំនងល្អជាមួយមិត្តភក្តិ ចេះយល់ចិត្ត អត់ឱនឲ្យគ្នាទៅវិញទៅមក បង្កើនជំនាញការគិតប្រកបដោយការត្រិះរិះពិចារណា និងផ្តល់ឱកាសឱ្យពួកគេបានគិតអំពីប្រធានបទអ្វីមួយ ឬប្រធានបទអំពីទស្សនៈផ្សេង។ មិនតែប៉ុណ្ណោះ វាផ្តល់ឱកាសដល់សិស្សានុសិស្សទទួលបាននូវបទពិសោធន៍ពីកន្លែងថ្មីៗច្រើនទៀត។

## ៥. បំបាត់ភាពធុញទ្រាន់ក្នុងថ្នាក់

ដំណើរទស្សនកិច្ចសិក្សា ធ្វើឲ្យសិស្សមានភាពអារម្មណ៍រំភើប និងសប្បាយរីករាយ។ វាផ្តល់ឱ្យពួកគេនូវអ្វីដែលត្រូវឆ្ពោះទៅមុខ ផ្តល់ឱ្យសិស្សនូវចំណាប់អារម្មណ៍ក្នុងការរៀន និងទទួលបានព័ត៌មានសិក្សាថ្មីៗ។

សរុបសេចក្តីមកដំណើរទស្សនកិច្ចសិក្សា ធ្វើឲ្យសិស្សទទួលបាននូវមេរៀនថ្មីៗក្នុងជីវិត បង្កើតចំណាប់អារម្មណ៍បំផុសគំនិត វិភាគអ្វីដែលបានរៀនក្នុងថ្នាក់ និងការរិះរកមធ្យោបាយផ្សេងៗដើម្បីដោះស្រាយបញ្ហាតាមជាក់ស្តែង ។



Ring Road St., Kor Kranh village, Siem Reap Commune. P O Box 93169, Post Code, 171209,
Siem Reap Province, Kingdom of Cambodia. Tel: (+855) 012 878 782/081 878 782 admin@issr.edu.kh

# កិច្ចប្រជុំប្រចាំខែជាមួយសិស្ស





អ្នកគ្រូ Dimple ជាគ្រូបង្រៀនឆ្នាំទី 5A និងជាគ្រូបច្ចេកទេសសម្របសម្រួល បានរៀបចំកិច្ចប្រជុំជួរជាមួយសិស្សប្រចាំខែឧសភានេះ។ គោលបំណងនៃកិច្ចប្រជុំជួរគឺដើម្បីផ្តល់នូវវេទិកាមួយសម្រាប់សិស្សានុសិស្សក្នុងការទំនាក់ទំនង និងចែករំលែកព័ត៌មានអំពីព្រឹត្តិការណ៍សំខាន់ៗដែលនឹងកើតឡើង។ម្យ៉ាងវិញទៀត សិស្សក៏អាចបង្ហាញពីគំនិត និងចំណេះដឹងផ្សេងៗដល់សិស្ស និងលោកគ្រូ អ្នកគ្រូ ផងដែរ។

## អំពីក្រុមប្រឹក្សាសិស្ស

**EVERYONE deserves a VOICE**

ក្រុមប្រឹក្សាសិស្សផ្នែកបឋមសិក្សា បានខិតខំប្រឹងប្រែងធ្វើការយ៉ាងខ្លាំង ដោយបានប្រជុំរៀងរាល់ពីរសប្តាហ៍ម្តង ដើម្បីពិភាក្សាអំពីជីវិតសិក្សា។ ពួកគេបានពិភាក្សាអំពីអ្វីដែលសំខាន់សម្រាប់ពួកគេ ហើយបានបោះឆ្នោតលើអ្វីដែលពួកគេនឹងធ្វើការ។ បច្ចុប្បន្ននេះ ពួកគេបាននិងកំពុងរចនាផ្លាកសញ្ញាសម្រាប់សមាជិកក្រុមប្រឹក្សាសាលា ក៏ដូចជាការពិភាក្សាអំពីរបៀបធ្វើឱ្យសិស្សសាលាអន្តរជាតិ ISSR កាន់តែមានភាពស្និទ្ធស្នាល។ សមាជិកក្រុមប្រឹក្សាសាលាជាច្រើនក៏បានស្ម័គ្រចិត្តធ្វើគម្រោងបន្ថែមដើម្បីបង្កើតវីដេអូអំពីសាលា។

# កម្មវិធីសិស្សឆ្នើមប្រចាំខែ

ជារៀងរាល់ខែ យើងទាំងអស់គ្នាទទួលស្គាល់សិស្សានុសិស្សដែលបានបង្ហាញលទ្ធផលសិក្សាឆ្នើម មានភាពជាអ្នកដឹកនាំ និងការចូលរួមពីសហគមន៍។ កម្មវិធីសិស្សឆ្នើមប្រចាំខែគឺជាពានរង្វាន់ដ៏មានកិត្យានុភាពដែលផ្តល់កិត្តិយសដល់លទ្ធផល និងការរួមចំណែករបស់កូនៗសិស្សានុសិស្ស។












Ring Road St., Kor Kranh village, Siem Reap Commune. P O Box 93169, Post Code, 171209,
Siem Reap Province, Kingdom of Cambodia. Tel: (+855) 012 878 782/081 878 782 admin@issr.edu.kh

# កម្មវិធីសំខាន់ៗប្រចាំខែឧសភា

ISSR PRESENTS:

## កម្មវិធីលេងទឹក

# Splash Day

ប្រព្រឹត្តទៅនៅថ្ងៃ សុក្រ ទី២៦ ខែឧសភា

**FRIDAY, MAY 26 AT PRIMARY POOL**

**R2–Y2: 8:15–9:40AM** **Y6–Y3: 10AM–12PM**



**PROGRAMME:**

- Presentation of swimming skills
- Performances
- Games
- Free play

Remember to bring:

- Swimsuit
- Goggles + cap
- Uniform for changing
- Towel(s)
- Flip-flops
- Water bottle + money for food

Ring Road St., Kor Kranh village, Siem Reap Commune. P O Box 93169, Post Code, 171209,
Siem Reap Province, Kingdom of Cambodia. Tel: (+855) 012 878 782/081 878 782 admin@issr.edu.kh

-ថ្ងៃប្រឡងប្រចាំត្រីមាសទី៣ : ថ្ងៃចន្ទទី០៨ ដល់ថ្ងៃព្រហស្បតិ៍ទី១១ ខែឧសភា

-ថ្ងៃប្រជុំបច្ចេកទេស : ថ្ងៃសុក្រទី១២ ខែឧសភា

## វគ្គសិក្សា SUMMER PROGRAMME

ចុះឈ្មោះថ្ងៃនេះនឹងទទួលបានការបញ្ចុះតម្លៃ៥%រហូតដល់ចប់ខែឧសភា ២០២៣!

ចូលរៀនចាប់ពីថ្ងៃចន្ទ ទី០៣ ខែឧសភា
ម៉ោងសិក្សា៖ ៨:០០ព្រឹក-១២:០០ថ្ងៃត្រង់




## ISSR

We are One, But We are Many

Contact Us

Ring Road St, Kor Kranh village, Siem Reap Commune. P O Box 93169, Post Code, 171209, Siem Reap Province, Kingdom of Cambodia.

Tel: (+855) 012 878 782/081 878 782
admin@issr.edu.kh

## SOCIAL MEDIA

Follow us on

1.Facebook page: https://www.facebook.com/issrprimary

2. Website: www.issr.edu.kh

## QUOTE OF THE MONTH

**FAIL = FIRST ATTEMPT IN LEARNING.**